# និន្នាការសេដ្ឋកិច្ចសង្គម

## Socio-Economic Trends

**ខែកក្កដា ឆ្នាំ២០១៩ /July 2019**

## មាតិកា


| | ទំព័រ |
|---|---|
| **ខ្លឹមសារសង្ខេប/Executive summary** | **១** |
| **១. និន្នាការសេដ្ឋកិច្ចកម្ពុជា/Cambodia economic trends** | **៣** |
| ១.១. សន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់/Consumer price index | ៣ |
| ១.២. វិស័យហិរញ្ញវត្ថុ/Finance | ៤ |
| ១.៣. វិស័យពាណិជ្ជកម្ម/Trade | ៥ |
| ១.៤. ការអនុវត្តថវិកា/Budget execution | ៨ |
| ១.៥. វិស័យវិនិយោគឯកជន/Private investment | ៩ |
| ១.៦. វិស័យទេសចរណ៍/Tourism | ១១ |
| ១.៧. វិស័យសំណង់/Construction | ១២ |
| **២. និន្នាការថ្លៃទំនិញសំខាន់ៗ /Commodity prices** | **១៤** |
| ២.១. ថ្លៃប្រេងឆៅ (Crude oil price: Brent, WTI, Dubai) | ១៤ |
| ២.២. ថ្លៃអង្ករ (Rice price: 5%, 25%, 100% broken) | ១៥ |
| ២.៣. ថ្លៃកៅស៊ូ (Rubber price: TSR20, SGP/MYS) | ១៦ |
| **៣. ឧបសម្ព័ន្ធ** | **១៧** |

## ខ្លឹមសារសង្ខេប / Executive summary

**១.** តាមរយៈទិន្នន័យផ្លូវការពីអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា (Admin Data) បានបង្ហាញថា ក្នុងរយៈពេល ៧ខែ ឆ្នាំ២០១៩ ការនាំចេញទំនិញចំនួន ២០ មុខ របស់កម្ពុជា នៅតែបន្តកំណើនរឹងមាំ ពោលគឺ សម្រេចបានក្នុងទំហំទឹកប្រាក់សរុប ៨ ០៦៥ លានដុល្លារ (**៣០,១% ធៀបនឹងផសស**[1]) កើនឡើង ១៤,៧% ធៀបនឹងរយៈពេលដូចគ្នាឆ្នាំមុន។ កំណើននេះបន្តរក្សាបាន ដោយសារ ១)ការបន្តកំណើនខ្ពស់នៃការនាំចេញផលិតផលកាត់ដេរនិងស្បែកជើង (១៥,៦%) ២)ការកើនឡើងនៃការនាំចេញអង្ករ(៩,២%) និង ៣)ការងើបឡើងវិញបន្តិចនៃកំណើននាំចេញកៅស៊ូ (០,៤%)។ ការនាំចេញទៅកាន់ទីផ្សារសំខាន់ៗ មានការប្រែប្រួលគួរឱ្យកត់សម្គាល់ ជាពិសេស ការនាំចេញទៅកាន់ទីផ្សារអាមេរិកនៅតែបន្តកំណើនខ្លាំងប្រមាណ ៤៤,២% នៅក្នុងឆ្នាំនេះ ខ្ពស់ជាងកំណើនក្នុងរយៈពេលដូចគ្នាឆ្នាំមុន ដែលមានអត្រា ២៥,១% ក្នុងនោះ ការនាំចេញផលិតផលវាយនភណ្ឌ មានការកើនឡើង ៣៩,៧% ធៀបនឹងរយៈពេលដូចគ្នាឆ្នាំមុន។ កំណើននេះ បានមកពីការចូលរួមមួយផ្នែកពីការទទួលបានប្រព័ន្ធអនុគ្រោះ Generalized System of Preferences (GSP) ពីសហរដ្ឋអាមេរិក លើការនាំចេញ Travel goods ពីកម្ពុជា។ ទន្ទឹមនេះ ការនាំចេញទៅកាន់ទីផ្សារអឺរ៉ុប (២៧ប្រទេស) មានកំណើនត្រឹមតែ ២,៧% ប៉ុណ្ណោះ ទាបជាងកំណើនក្នុងរយៈពេលដូចគ្នាឆ្នាំមុន ដែលមានអត្រា ១៣,៤%។ ចំណែកឯ ការនាំចូល មានទំហំទឹកប្រាក់សរុបចំនួន ១១ ៨៧៦ លានដុល្លារ **(៤៤,៣% បើធៀបនឹងផសស)** បានកើនឡើង ២១,៩% ធៀបនឹងរយៈពេលដូចគ្នាឆ្នាំមុន។ កំណើនខ្ពស់នៃការនាំចូលនេះត្រូវបានជំរុញដោយ កំណើនខ្ពស់នៃការនាំចូលសម្ភារសំណង់ (៦៨,៣%) គ្រឿងយន្ត (៩២,៦%) និងប្រេងឥន្ធនៈ (៦១,៦%)។ មួយវិញទៀត ការនាំចូលផលិតផលវាយនភណ្ឌ[2] នៅតែបន្តថមថយកំណើន ពី ២៧,៤% នៅរយៈពេល ៧ខែឆ្នាំ២០១៨ មកត្រឹម ០,៦% នៅរយៈពេល ៧ខែ ឆ្នាំ២០១៩ ដោយសារការថយចុះនៃការនាំចូលក្រណាត់ដែលជាវត្ថុធាតុដើមសម្រាប់ប្រើប្រាស់ក្នុងឧស្សាហកម្មកាត់ដេរ។

**២.** ក្នុងរយៈពេល ៧ខែ ឆ្នាំ២០១៩នេះ កម្ពុជាទទួលបានភ្ញៀវទេសចរអន្តរជាតិសរុបប្រមាណ **៣,៨ លាននាក់ កើនឡើង ១១,១%** ធៀបនឹងរយៈពេលដូចគ្នាឆ្នាំមុន ក្នុងនោះភ្ញៀវទេសចរចិនមានចំនួន ១,៥ លាននាក់ ឬ ៣៩% នៃភ្ញៀវទេសចរអន្តរជាតិសរុប (កើនឡើង ៣៧%), វៀតណាម ១២,៥% (កើនឡើង ៤,៦%), ឡាវ ៥,៧% (ថយចុះ -១,៩%) និងបន្តបន្ទាប់រួមមាន ថៃ, កូរ៉េខាងត្បូង, អាមេរិក, ម៉ាឡេស៊ី, អង់គ្លេស, និងបារាំង។ ក្នុងកំណើនសរុប ១១,១%នេះ ភ្ញៀវទេសចរចិនបានចូលរួមចំណែកកំណើន (contribution to growth) ១១,៧%។ ទោះបីជា ចំនួនភ្ញៀវទេសចរអន្តរជាតិសរុបមានការកើនឡើងក៏ដោយ ប៉ុន្តែចំណូលសរុបទូទៅពីវិស័យនេះបានធ្លាក់ចុះក្នុងអត្រា -១៩,១% បើធៀបនឹងរយៈពេល ៧ខែឆ្នាំមុន ពោលគឺថយចុះពី ២៥៩,២ ប៊ីលានរៀល នៅឆ្នាំ២០១៨ មកត្រឹម ២០៩,៧ ប៊ីលានរៀល ក្នុងឆ្នាំ២០១៩ (ប្រភព÷ TOFE ២០១៩, MEF)។

**៣.** នៅខែកក្កដា ឆ្នាំ២០១៩នេះ សន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់និងសេវាកម្មនៅរាជធានីភ្នំពេញ ***បានកើនឡើង ០,៥% ធៀបនឹងខែមុន និង ២,២% ធៀបនឹងខែដូចគ្នាឆ្នាំមុន។*** ក្នុងនោះ សន្ទស្សន៍ថ្លៃទំនិញសំខាន់ៗមានកំណើនគួរឱ្យកត់សម្គាល់ ដូចជា សន្ទស្សន៍ថ្លៃអាហារនិងភេសជ្ជៈមិនមានជាតិស្រវឹង កើនឡើង ២,២%, ភេសជ្ជៈមានជាតិស្រវឹង និងថ្នាំជក់កើន ៦,៣%, ផ្ទះសំបែង ទឹក អគ្គិសនី ឧស្ម័ន និងឥន្ធនៈដទៃទៀតកើន ១,៧% និងភោជនីយដ្ឋានកើន ៦,១%។ ***តាមការធ្វើចំណោលដល់ខែធ្នូ ឆ្នាំ២០១៩***

---

[1] ផសស (GDP at current price Million US$) = **២៦ ៧៨៦** លានដុល្លារ÷ យោងតាមតារាងMacro-framework ថ្ងៃទី២៣ ខែមេសា ឆ្នាំ២០១៩។

[2] ការនាំចូលផលិតផលវាយនភណ្ឌ បូករួមទាំង សំលៀកបំពាក់ចាស់ ផលិតផលវាយនភណ្ឌថ្មី និងក្រណាត់

***អត្រាអតិផរណាប្រចាំឆ្នាំ** (Year on Year) **និងអតិផរណាមធ្យមប្រចាំឆ្នាំ** (Year Average) **អាចមានអត្រាកំណើន ២,៧% និង ២,០% រៀងគ្នា។***

**៤.** គិតត្រឹមខែកក្កដា ឆ្នាំ២០១៩ រដ្ឋបាលថ្នាក់ជាតិប្រមូលចំណូលក្នុងស្រុកសរុបបានចំនួន **១៣ ៥៤៩,៨** ប៊ីលានរៀល ឬស្មើនឹង **៦៨,៥%** នៃច្បាប់ឆ្នាំ២០១៩ បានកើនឡើង **២៤%** ធៀបនឹងរយៈពេលដូចគ្នាឆ្នាំមុន ដោយសារ ការកើនឡើងខ្លាំងនៃការប្រមូលចំណូលសារពើពន្ធ ជាពិសេស កំណើននៃការប្រមូលចំណូលពីពន្ធប្រយោល **(២៦,៤%)** ចំណូលពីពន្ធពាណិជ្ជកម្មក្រៅប្រទេស **(២៦,២%)** និងចំណូលពីពន្ធផ្ទាល់ **(១៥,៦%)**។ ទន្ទឹមនេះ រដ្ឋបាលថ្នាក់ជាតិអនុវត្តចំណាយសរុបបានចំនួន **១០ ៦៩៥** ប៊ីលានរៀល ឬស្មើនឹង **៤៣,៤%** នៃច្បាប់២០១៩ បានថយចុះ **៤,១%** បើធៀបនឹងរយៈពេលដូចគ្នាឆ្នាំមុន។ **ជាលទ្ធផល គិតត្រឹមខែកក្កដា ឆ្នាំ២០១៩ តុល្យភាពថវិកាចរន្តមានអតិរេកសាច់ប្រាក់ចំនួន ៥ ៦៣៣,៦ ប៊ីលានរៀល។**

**៥.** ក្នុងរយៈពេល ៧ខែ ឆ្នាំ២០១៩នេះ គម្រោងវិនិយោគឯកជនសរុបដែលទទួលបានការអនុញ្ញាតដោយក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជាមានចំនួន **១២២** គម្រោង កើនឡើង ៥៣ គម្រោង និងមានទុនវិនិយោគប្រមាណ **៤ ៧៣៦** លានដុល្លារអាមេរិក កើនឡើង ៦២,៦% ធៀបនឹងរយៈពេលដូចគ្នាឆ្នាំមុន។ យោងតាមទិន្នន័យដែលទទួលបាន សង្កេតឃើញថា ក្នុងខែកក្កដានេះ មានការបោះទុនវិនិយោគលើគម្រោងថ្មី គឺរោងចក្របន្ទះសូឡា (Solar Panel) ដែលមានទុនវិនិយោគ ៦,៦ លានដុល្លារអាមេរិក (ភាគហ៊ុនិក ហុងកុង ៤៩%, ចិន ៥១%)។ គម្រោងវិនិយោគនៅតែបន្តកើនឡើង ដោយសារ ១)ការផ្តល់ការលើកទឹកចិត្តទាំងផ្នែកពន្ធ និងមិនមែនពន្ធដល់វិនិយោគិនបរទេស និង ២)ការបន្តរក្សាស្ថិរភាពសេដ្ឋកិច្ច និងនយោបាយក្នុងស្រុក។

**៦.** ក្នុងរយៈពេល ៧ខែ ឆ្នាំ២០១៩នេះ សំណើសុំសាងសង់សរុបមានចំនួន ២ ៤៧៧ គម្រោង កើនឡើង ៥០០ គម្រោង (ភាគច្រើនជាប្រភេទសំណង់លំនៅដ្ឋាន និងឧស្សាហកម្ម) ក្នុងផ្ទៃក្រឡា ៩,១ លានម៉ែត្រការ៉េ កើនឡើង ២៤% និងមានតម្លៃ ៤,៥ ប៊ីលានដុល្លារអាមេរិក កើនឡើង ៥១,៦% ធៀបនឹងរយៈពេលដូចគ្នាឆ្នាំមុន។ កំណើននេះ បង្ហាញពីការកើនឡើងនៃកំណើនវិនិយោគលើវិស័យសំណង់ ជាពិសេស សំណង់លំនៅដ្ឋាននៅរាជធានីភ្នំពេញ។

**៧.** គិតត្រឹមខែកក្កដា ឆ្នាំ២០១៩ រូបិយវត្ថុទូទៅ M2 មានចំនួន ៩៧,៨ ទ្រីលានរៀល បានកើនឡើង ២៦,៤% ធៀបនឹងឆ្នាំមុន ក្នុងនោះប្រាក់រៀលចរាចរលើទីផ្សារមានចំនួន ១៥,៤ ទ្រីលានរៀល។ ឥណទានផ្តល់ដោយគ្រឹះស្ថានធនាគារមានចំនួន ៩៧,១ ទ្រីលានរៀល បានកើនឡើង ២៧,៩%។ ក្នុងឆ្នាំ២០១៩នេះ ឥណទានផ្តល់ដល់វិស័យសេវាកម្ម និងវិស័យសំណង់បន្តមានកំណើនខ្ពស់ ខណៈពេលដែលកំណើនឥណទានដល់វិស័យកសិកម្ម និងឧស្សាហកម្មបន្តថមថយធៀបនឹងបណ្តាឆ្នាំកន្លងទៅ។ តម្លៃប្រាក់រៀលបានបន្តថយចុះក្នុងខែកក្កដា ដោយអត្រាប្តូរប្រាក់រៀលធៀបនឹងដុល្លារអាមេរិកស្មើ ៤ ០៨៦ រៀល/ ដុល្លារ។

**៨.** នៅក្នុងខែកក្កដា ឆ្នាំ២០១៩ ថ្លៃប្រេងសាំងធម្មតា និងប្រេងម៉ាស៊ូតលើទីផ្សារកម្ពុជា ព្រមទាំងថ្លៃប្រេងឆៅលើទីផ្សារអន្តរជាតិមានការកើនឡើងវិញបន្តិច ធៀបនឹងខែមុន។ ថ្លៃអង្ករលេខ១ និងអង្ករលេខ២លើទីផ្សារកម្ពុជាពុំមានការប្រែប្រួល តែថ្លៃអង្ករថៃនាំចេញទៅទីផ្សារអន្តរជាតិមានការប្រែប្រួលបន្តិចបន្តួចធៀបនឹងខែមុន។ នៅក្នុងខែកក្កដា ឆ្នាំ២០១៩ ថ្លៃកៅស៊ូ (គ្រួសារជ័រកៅស៊ូស្ងួត) លើទីផ្សារកម្ពុជា ព្រមទាំងថ្លៃកៅស៊ូស្តង់ដារ (កៅស៊ូថៃ TSR20 និងកៅស៊ូថៃ RSS3) លើទីផ្សារអន្តរជាតិ មានការថយចុះធៀបនឹងខែមុន។

********

# ៣. ឧបសម្ព័ន្ធ

## ១. និន្នាការសេដ្ឋកិច្ចកម្ពុជា / Cambodia economic trends

### ១.១. ស្ថានភាពសន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់ / Consumer price index

**តារាង ១.១ក÷ បម្រែបម្រួលសន្ទស្សន៍ថ្លៃនៃក្រុមទំនិញទាំង១២ (គិតជា%)**

| បរិយាយ | ២០១៩ | | | | ២០១៩ | | | |
|---|---|---|---|---|---|---|---|---|
| | ធៀបនឹងខែមុន (MoM) | | | | ធៀបនឹងឆ្នាំមុន (YoY) | | | |
| | មេសា | ឧសភា | មិថុនា | កក្កដា | មេសា | ឧសភា | មិថុនា | កក្កដា |
| **មុខទំនិញគ្រប់មុខ** | 0.3 | 0.2 | -0.4 | 0.5 | 2.1 | 2.0 | 1.4 | 2.2 |
| ១-អាហារនិងភេសជ្ជៈមិនមានជាតិស្រវឹង | 0.6 | 0.3 | -0.6 | 0.6 | 1.9 | 1.9 | 1.1 | 2.2 |
| ២-ភេសជ្ជៈមានជាតិស្រវឹងនិងថ្នាំជក់ | -0.1 | 0.0 | 0.2 | 0.2 | 5.0 | 5.4 | 5.3 | 6.3 |
| ៣-សម្លៀកបំពាក់និងស្បែកជើង | 0.2 | -0.6 | -0.2 | 1.0 | 3.4 | 3.0 | 2.2 | 3.5 |
| ៤-ផ្ទះសំបែង ទឹក អគ្គិសនី ឧស្ម័ននិងឥន្ធនៈដទៃទៀត | 0.1 | 0.1 | -0.6 | 0.3 | 1.9 | 1.8 | 1.3 | 1.7 |
| ៥-គ្រឿងសង្ហារឹម សម្ភារៈប្រើប្រាស់និងការថែទាំ | 0.1 | -0.7 | -0.1 | 0.2 | 1.5 | 0.7 | 0.8 | 1.3 |
| ៦-សុខាភិបាល | 0.0 | -0.1 | 0.0 | -0.1 | 1.5 | 1.4 | 1.5 | 1.4 |
| ៧-ការដឹកជញ្ជូន | 1.5 | 0.5 | -1.2 | 0.1 | -0.8 | -1.0 | -2.5 | -1.4 |
| ៨-គមនាគមន៍ | 1.5 | 0.4 | -1.2 | 0.1 | -0.6 | -0.2 | -1.2 | -1.1 |
| ៩-ការកំសាន្តនិងវប្បធម៌ | 0.1 | 0.0 | 0.5 | 0.2 | 0.6 | 0.9 | 0.7 | 1.1 |
| ១០-ការសិក្សា | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | -0.4 |
| ១១-ភោជនីយដ្ឋាន | -1.5 | 0.0 | 1.1 | 0.3 | 6.6 | 6.1 | 7.2 | 6.1 |
| ១២-ទំនិញនិងសេវាកម្មផ្សេងៗ | 0.1 | 0.0 | 0.4 | 0.7 | 1.1 | 1.0 | 1.4 | 1.8 |

*ប្រភព÷ វិទ្យាស្ថានជាតិស្ថិតិ (NIS)*

*សម្គាល់÷ ក្នុងតារាង (,) ស្មើកាត់ខ្ទង់ និង (.) ស្មើក្បៀស*

**តារាង ១.១ខ÷ បម្រែបម្រួលសន្ទស្សន៍ថ្លៃម្ហូបអាហារមួយចំនួន (គិតជា%)**

| បរិយាយ | ២០១៩ | | | | ២០១៩ | | | |
|---|---|---|---|---|---|---|---|---|
| | ធៀបនឹងខែមុន (MoM) | | | | ធៀបនឹងឆ្នាំមុន (YoY) | | | |
| | មេសា | ឧសភា | មិថុនា | កក្កដា | មេសា | ឧសភា | មិថុនា | កក្កដា |
| អង្ករ | 0.4 | 0.8 | -0.5 | 0.7 | 3.0 | 3.6 | 2.7 | 3.5 |
| សាច់គោ | 0.2 | -0.1 | 0.1 | 0.5 | 1.1 | 0.5 | 1.1 | 1.9 |
| សាច់មាន់ | 0.3 | 0.1 | -1.2 | 0.9 | 3.5 | 3.3 | 1.7 | 2.5 |
| សាច់ទា | 0.4 | 0.9 | -1.6 | 2.2 | 3.0 | 4.0 | 2.8 | 2.8 |
| សាច់ជ្រូក | 2.1 | -0.8 | -0.4 | -5.0 | 2.4 | 1.6 | 1.0 | -3.9 |
| ត្រីទឹកសាប និងត្រីទឹកសមុទ្រ | 0.7 | 0.1 | -0.4 | 3.0 | 2.3 | 1.5 | 0.7 | 4.6 |
| ក្នុងនោះត្រីស្រស់ | 0.7 | 0.2 | -0.3 | 3.5 | 1.4 | 0.7 | -0.1 | 4.5 |
| ផ្លែឈើ | -0.3 | 1.2 | 0.0 | 1.1 | -0.6 | 1.3 | 1.1 | 3.1 |
| ផ្លែឈើស្រស់ | -0.4 | 1.4 | 0.0 | 1.3 | -0.8 | 1.4 | 1.2 | 3.7 |

| | | | | | | | | |
|---|---|---|---|---|---|---|---|---|
| បន្លែ | 1.1 | 1.3 | -2.1 | 1.4 | 2.7 | 3.2 | 1.0 | 3.0 |
| បន្លែជាស្លឹក | 0.9 | 0.2 | -2.1 | 0.6 | 4.7 | 3.9 | 1.0 | 1.1 |
| បន្លែជាផ្លែ | 2.3 | 3.1 | -2.6 | 2.6 | 2.6 | 5.5 | 3.3 | 7.9 |

*ប្រភព÷ វិទ្យាស្ថានជាតិស្ថិតិ (NIS)*

*សម្គាល់÷ ក្នុងតារាង (,) ស្មើកាត់ខ្ទង់ និង (.) ស្មើក្បៀស*

## ១.២. វិស័យហិរញ្ញវត្ថុ / Finance

### ១.២.១. ផ្នែករូបិយវត្ថុនិងធនាគារ

**តារាង ១.២.១ក÷ ស្ថានភាពរូបិយវត្ថុក្នុងខែកក្កដា ឆ្នាំ២០១៩ (ប៊ីលានរៀល, %)**

| សូចនាកររូបិយវត្ថុ | ២០០៥ | ២០១០ | ២០១៥ | ២០១៨ | ២០១៩ | | | Δ(%) | | |
|---|---|---|---|---|---|---|---|---|---|---|
| | ធ្នូ | ធ្នូ | ធ្នូ | ធ្នូ | ឧសភា | មិថុនា | កក្កដា | ខែមុន | ១ឆ្នាំមុន | CAGR5 |
| **រូបិយវត្ថុទូទៅ M2** | **5,025** | **19,477** | **48,868** | **88,443** | **94,947** | **96,247** | **97,848** | **2.6%** | **26.4%** | **21.9%** |
| រូបិយវត្ថុក្រៅធនាគារជាតិ (៛) | 1,282 | 3,099 | 5,942 | 9,255 | 9,704 | 10,036 | 10,655 | 6.2% | 20.9% | 15.6% |
| ប្រាក់បញ្ញើចរន្ត (៛) | 41 | 122 | 844 | 971 | 1,383 | 1,238 | 1,310 | 5.8% | 22.2% | 18.0% |
| បញ្ញើមានកាលកំណត់និងសន្សំ (៛) | 113 | 408 | 1,550 | 3,209 | 3,095 | 3,336 | 3,475 | 4.2% | 32.3% | 27.7% |
| បញ្ញើជារូបិយប័ណ្ណបរទេស (FCD) | 3,589 | 15,848 | 40,532 | 75,008 | 80,764 | 81,637 | 83,308 | 2.0% | 27.0% | 22.7% |
| **អត្រា FCD/M2 (%)** | **71.4%** | **81.4%** | **82.9%** | **84.8%** | **85.1%** | **84.8%** | **84.4%** | -- | -- | -- |
| **អត្រា M1/M2 (%)** | **26.3%** | **16.5%** | **13.9%** | **11.6%** | **11.7%** | **11.7%** | **12.1%** | -- | -- | -- |

*ប្រភព÷ ធនាគារជាតិនៃកម្ពុជា*

*សម្គាល់÷ ក្នុងតារាង (,) ស្មើកាត់ខ្ទង់ និង (.) ស្មើក្បៀស*

**តារាង ១.២.១ខ÷ ស្ថានភាពរូបិយវត្ថុក្នុងខែកក្កដា ឆ្នាំ២០១៩ (ប៊ីលានរៀល, %)**

| សូចនាកររូបិយវត្ថុ | ២០០៥ | ២០១០ | ២០១៥ | ២០១៨ | ២០១៩ | | | Δ(%) | | |
|---|---|---|---|---|---|---|---|---|---|---|
| | ធ្នូ | ធ្នូ | ធ្នូ | ធ្នូ | ឧសភា | មិថុនា | កក្កដា | ខែមុន | ១ឆ្នាំមុន | CAGR5 |
| **មូលដ្ឋានរូបិយវត្ថុ** (MB) | **2,637** | **10,245** | **22,501** | **44,157** | **46,476** | **46,929** | **48,267** | **2.9%** | **24.5%** | **24.4%** |
| រូបិយវត្ថុក្រៅធនាគារជាតិ (៛) | 1,282 | 3,099 | 5,942 | 9,255 | 9,704 | 10,036 | 10,655 | 6.2% | 20.9% | 15.6% |
| រូបិយវត្ថុនៅធនាគារជាតិ (៛) | 27 | 140 | 362 | 737 | 969 | 894 | 864 | 3.3% | 11.0% | 19.2% |
| ប្រាក់បញ្ញើពីធនាគារ | 1,322 | 6,978 | 15,901 | 34,106 | 35,595 | 35,885 | 36,658 | 2.2% | 26.4% | 28.1% |
| ប្រាក់បញ្ញើពីស្ថាប័នផ្សេងៗ | 6 | 28 | 296 | 58 | 207 | 114 | 90 | -21.2% | -48.9% | 17.4% |
| **អត្រា M2/MB** (%) | **190.5** | **190.1** | **217.2** | **200.3** | **204.3** | **205.1** | **204.6** | -- | -- | -- |

*ប្រភព÷ ធនាគារជាតិនៃកម្ពុជា*

*សម្គាល់÷ ក្នុងតារាង (,) ស្មើកាត់ខ្ទង់ និង (.) ស្មើក្បៀស*

| តារាង ១.២.១ក÷ ឥណទានផ្តល់ដោយគ្រឹះស្ថានធនាគារ (ប៊ីលានរៀល, %) | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|
| សូចនាករ | ២០១០ | ២០១៥ | ២០១៨ | ២០១៩ | | | Δ (%) | | |
| | ធ្នូ | ធ្នូ | ធ្នូ | ឧសភា | មិថុនា | កក្កដា | ខែមុន | ១ឆ្នាំមុន | CAGR5 |
| **ឥណទានផ្តល់ដោយគ្រឹះស្ថានធនាគារ** | **13,221** | **47,946** | **84,736** | **92,622** | **95,033** | **97,140** | **2.2%** | **29.1%** | **23.2%** |
| ឥណទានផ្តល់ដល់គ្រឹះស្ថានហិរញ្ញវត្ថុ | 177 | 1,169 | 3,014 | 3,598 | 3,816 | 3,911 | 2.5% | 37.0% | 45.0% |
| ឥណទានផ្តល់ដល់គ្រឹះស្ថានមិនមែនហិរញ្ញវត្ថុ | 11,695 | 39,807 | 64,979 | 70,246 | 71,662 | 73,024 | 1.9% | 25.3% | 20.4% |
| វិស័យសេវាកម្ម | 8,675 | 27,380 | 44,898 | 49,147 | 50,224 | 51,387 | 2.3% | 28.0% | 21.3% |
| វិស័យកសិកម្ម | 884 | 4,973 | 7,524 | 7,511 | 7,532 | 7,573 | 0.5% | 7.4% | 21.1% |
| វិស័យឧស្សាហកម្ម | 1,205 | 3,960 | 4,770 | 4,842 | 5,023 | 5,053 | 0.6% | 15.6% | 6.8% |
| វិស័យសំណង់ | 931 | 3,493 | 7,787 | 8,747 | 8,883 | 9,011 | 1.4% | 34.0% | 27.6% |
| ឥណទានតម្រូវការផ្ទាល់ខ្លួននិងផ្សេងៗ | 1,349 | 6,971 | 16,744 | 18,778 | 19,555 | 20,205 | 3.3% | 43.4% | 35.5% |
| ឥណទានតម្រូវការផ្ទាល់ខ្លួន | 1,183 | 6,110 | 15,707 | 17,829 | 18,582 | 19,244 | 3.6% | 47.35 | 40.4% |
| ឥណទានផ្សេងៗ | 166 | 861 | 1037 | 949 | 973 | 961 | -1.1% | -5.7% | 5.6% |

*ប្រភព÷ ធនាគារជាតិនៃកម្ពុជា*

*សម្គាល់÷ ក្នុងតារាង (,) ស្មើកាត់ខ្ទង់ និង (.) ស្មើក្បៀស*

| តារាង ១.២.១ឃ÷ សមាមាត្រឥណទានផ្តល់ដោយធនាគារពាណិជ្ជ (ប៊ីលានរៀល, %) | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|
| សូចនាករ | ២០១០ | ២០១១ | ២០១២ | ២០១៣ | ២០១៤ | ២០១៥ | ២០១៦ | ២០១៧ | ២០១៨ | ២០១៩ |
| | ធ្នូ | ធ្នូ | ធ្នូ | ធ្នូ | ធ្នូ | ធ្នូ | ធ្នូ | ធ្នូ | ធ្នូ | កក្កដា |
| **ឥណទានផ្តល់ដោយធនាគារ (ប៊ីលានរៀល)** | **13,221** | **17,680** | **23,772** | **29,835** | **38,839** | **47,946** | **47,946** | **68,271** | **84,736** | **97,140** |
| **កំណើនឥណទានផ្តល់ដោយធនាគារ (%)** | **25.4** | **33.7** | **34.5** | **25.5** | **30.2** | **23.4** | **19.0** | **19.7** | **24.1** | -- |
| **កំណើនពិតនៃផ.ស.ស (%)** | **6.0** | **7.1** | **7.3** | **7.4** | **7.1** | **7.0** | **7.0** | **7.0** | **7.5** | -- |
| **សមាមាត្រឥណទានផ្តល់ដោយធនាគារ (%)** | **100.0** | **100.0** | **100.0** | **100.0** | **100.0** | **100.0** | **100.0** | **100.0** | **100.0** | **100.0** |
| ឥណទានផ្តល់ដល់គ្រឹះស្ថានហិរញ្ញវត្ថុ | 1.3 | 1.8 | 2.3 | 1.6 | 2.0 | 2.4 | 1.8 | 2.7 | 3.6 | 4.0 |
| ឥណទានផ្តល់ដល់គ្រឹះស្ថានមិនមែនហិរញ្ញវត្ថុ | 88.5 | 85.2 | 85.9 | 86.1 | 85.1 | 83.0 | 82.0 | 79.6 | 76.7 | 75.2 |
| *វិស័យកសិកម្ម* | *6.7* | *8.9* | *9.6* | *9.7* | *10.0* | *10.4* | *10.8* | *10.3* | *8.9* | *7.8* |
| *វិស័យឧស្សាហកម្ម* | *9.1* | *9.2* | *9.6* | *11.5* | *9.5* | *8.3* | *7.4* | *6.6* | *5.6* | *5.2* |
| *វិស័យសេវាកម្ម* | *65.6* | *59.6* | *59.1* | *57.2* | *57.5* | *57.1* | *55.2* | *53.3* | *53.0* | *52.9* |
| *វិស័យសំណង់* | *7.0* | *7.4* | *7.5* | *7.7* | *8.1* | *7.3* | *8.7* | *9.3* | *9.2* | *9.3* |
| ឥណទានតម្រូវការផ្ទាល់ខ្លួន | 9.0 | 11.3 | 9.8 | 9.7 | 10.9 | 12.7 | 14.7 | 16.2 | 18.5 | 19.8 |
| ឥណទានផ្សេងៗ | 1.3 | 1.7 | 2.0 | 2.6 | 2.1 | 1.8 | 1.5 | 1.4 | 1.2 | 1.0 |
| **អត្រាឥណទានមិនដំណើរការ (%)** | **3.05** | **2.43** | **2.45** | **2.70** | **2.22** | **1.99** | **2.40** | **2.40** | **2.20** | -- |

*ប្រភព÷ ធនាគារជាតិនៃកម្ពុជា, ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ*

*សម្គាល់÷ ក្នុងតារាង (,) ស្មើកាត់ខ្ទង់ និង (.) ស្មើក្បៀស*

## ១.២.២. ផ្នែកទីផ្សារមូលបត្រ

| តារាង ១.២.២ក÷ ការជួញដូរមូលបត្រកម្មសិទ្ធិលើទីផ្សារមូលបត្រកម្ពុជា (ពាន់ភាគហ៊ុន, លានរៀល) | | | | | | | |
|---|---|---|---|---|---|---|---|
| **សូចនាករ** | **២០១៥** | **២០១៦** | **២០១៧** | **២០១៨** | **៧ខែ២០១៩** | **ធៀប៧ខែឆ្នាំមុន** | **១៨/១៧** |
| សន្ទស្សន៍ផ.ម.ក (គិតត្រឹមចុងគ្រា) | 399.10 | 356.31 | 344.56 | 489.35 | 621.41 | 83.6% | 42.0% |
| បរិមាណជួញដូរ (ពាន់ភាគហ៊ុន) | 1,422 | 2,614 | 3,624 | 3,781 | 14,342 | 1,319.4% | 4.4% |
| តម្លៃជួញដូរ (លានរៀល) | 7,040 | 10,024 | 12,570 | 24,902 | 139,163 | 3,134.3% | 98.1% |

*ប្រភព÷ ទីផ្សារមូលបត្រកម្ពុជា*

*សម្គាល់÷ ក្នុងតារាង (,) ស្មើកាត់ខ្ទង់ និង (.) ស្មើក្បៀស*

| តារាង ១.២.២ខ÷ ព័ត៌មានមូលបត្រកម្មសិទ្ធិលើទីផ្សារមូលបត្រកម្ពុជា (រៀល, ភាគហ៊ុន) | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|
| ភាគហ៊ុនចុះបញ្ជី | ២០១៣ | ២០១៤ | ២០១៥ | ២០១៦ | ២០១៧ | ២០១៨ | កក្កដា-១៩ | ចំនួនភាគហ៊ុនចុះបញ្ជី | ចំនួនភាគហ៊ុនបោះផ្សាយ |
| តម្លៃបិទទីផ្សារ | | | | | | | | | |
| PPWSA | 5,360 | 4,400 | 5,080 | 4,100 | 3,860 | 4,200 | 6,040 | 86,973,162 | 13,045,975 |
| GTI | -- | 6,900 | 4,020 | 4,320 | 4,700 | 4,320 | 4,780 | 40,000,000 | 8,000,000 |
| PPAP | -- | -- | 5,500 | 5,300 | 5,140 | 7,680 | 9,240 | 20,684,365 | 4,136,873 |
| PPSP | -- | -- | -- | 2,860 | 2,820 | 2,900 | 2,750 | 57,875,000 | 15,575,000 |
| PAS | -- | -- | -- | -- | 5,100 | 10,100 | 13,800 | 85,771,967 | 21,442,992 |

*ប្រភព÷ ផ្សារមូលបត្រកម្ពុជា*

*សម្គាល់÷ ក្នុងតារាង (,) ស្មើកាត់ខ្ទង់ និង (.) ស្មើក្បៀស*

| តារាង ១.២.២គ÷ ព័ត៌មានមូលបត្របំណុលលើទីផ្សារមូលបត្រកម្ពុជា | | | |
|---|---|---|---|
| សញ្ញាបណ្ណ | HKL21A | LOLC22A | LOLC22B |
| ទឹកប្រាក់ (លានរៀល) | 120,000 | 53,600 | 26,400 |
| ចំនួនសញ្ញាបណ្ណ (ចំនួន) | 1,200,000 | 536,000 | 264,000 |
| តម្លៃចារឹក (រៀល) | 100,000 | 100,000 | 100,000 |
| ឥណប្រតិទាន (ឆ្នាំ) | 3 | 3 | 3 |
| អត្រាការប្រាក់ | 8.50% | 8.00% | 9.00% |
| ថ្ងៃបោះផ្សាយ | ១៤-វិច្ឆិកា-២០១៨ | ២៦-មេសា-២០១៩ | ២៦-មេសា-២០១៩ |
| ថ្ងៃដល់ឥណប្រតិទាន | ១៤-វិច្ឆិកា-២០២១ | ២៦-មេសា-២០២២ | ២៦-មេសា-២០២២ |

*ប្រភព÷ ផ្សារមូលបត្រកម្ពុជា*

*សម្គាល់÷ ក្នុងតារាង (,) ស្មើកាត់ខ្ទង់ និង (.) ស្មើក្បៀស*

## ១.៣. វិស័យពាណិជ្ជកម្ម / Trades

តារាង ១.៣÷ ការនាំចូលនិងការនាំចេញតាមមុខទំនិញសំខាន់ៗក្នុងខែកក្កដា ឆ្នាំ២០១៩ (លានដុល្លារ)

| សូចនាករ | ២០១៦ ១២ខែ | ២០១៧ ១២ខែ | ២០១៨ ១២ខែ | ២០១៩ | | | | Δ% | |
|---|---|---|---|---|---|---|---|---|---|
| | | | | ឧសភា | មិថុនា | កក្កដា | ៧ខែ | ខែមុន | ៧ខែឆ្នាំមុន |
| **តម្លៃនាំចូលសរុប (I)** | **12,243** | **13,615** | **16,876** | **1,908.4** | **1,740.0** | **1,913.0** | **11,875.8** | **9.9%** | **21.9%** |
| វាយនភណ្ឌ | 3,573 | 3,776 | 4,592 | 476.0 | 442.1 | 336.3 | 2,781.3 | **-23.9%** | **0.6%** |
| បរិក្ខារសំណង់ | 551 | 621 | 953 | 168.1 | 148.3 | 141.4 | 878.8 | **4.7%** | **68.5%** |
| គ្រឿងយន្ត | 1,027 | 1,158 | 1,452 | 180.9 | 187.3 | 185.1 | 1,196.0 | **1.2%** | **53.1%** |
| ប្រេងឥន្ធនៈ | 1,276 | 887 | 1,124 | 148.5 | 148.8 | 146.3 | 1,015.1 | **1.7%** | **90.0%** |
| ផ្សេងៗ | 5,816 | 7,173 | 8,755 | 934.8 | 813.5 | 1,103.9 | 6,004.5 | **35.7%** | **16.8%** |
| **តម្លៃនាំចេញសរុប (II)** | **10,184** | **11,142** | **12,739** | **1,195.1** | **1301.6** | **1,455.4** | **8,065.0** | **11.8%** | **14.7%** |
| វាយនភណ្ឌ និងស្បែកជើង | 7,449 | 8,020 | 9,507 | 903.7 | 989.4 | 1,055.3 | 6,045.0 | **6.7%** | **15.6%** |
| អង្ករ | 301 | 329 | 414 | 24.0 | 21.6 | 20.1 | 214.7 | **-6.6%** | **9.2%** |
| កៅស៊ូ | 165 | 254 | 218 | 13.5 | 15.0 | 19.7 | 105.6 | **31.1%** | **0.4%** |
| ផ្សេងៗ | 2,269 | 2,539 | 2,600 | 253.9 | 275.7 | 360.3 | 1,699.6 | **30.7%** | **13.4%** |
| **តុល្យភាពពាណិជ្ជកម្ម (II - I)** | **-2,059** | **-2,473** | **-4,138** | **-713.3** | **-438.4** | **-457.6** | **-3,810.8** | **--** | **--** |

*ប្រភពទិន្នន័យ÷ អគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា*
*សម្គាល់÷ ក្នុងតារាង (,) ស្មើកាត់ខ្នង់ និង (.) ស្មើក្បៀស*

## ១.៤. ស្ថានភាពការអនុវត្តថវិការដ្ឋ / Budget execution

តារាង ១.៤÷ ការអនុវត្តចំណូលនិងចំណាយ (គិតជាប៊ីលានរៀល)

| បរិយាយ | ២០១៩ ៦ខែ | ការអនុវត្ត ២០១៨ | | | ការអនុវត្ត ២០១៩ | | | Δ% | |
|---|---|---|---|---|---|---|---|---|---|
| | | ឧសភា | មិថុនា | កក្កដា | ឧសភា | មិថុនា | កក្កដា | ខែកក្កដា ឆ្នាំមុន | ៧ខែ ឆ្នាំមុន |
| **១. ចំណូលសរុប** | **11,414.18** | **1,574.75** | **1,548.05** | **1,499.26** | **1,961.00** | **2,115.20** | **2,097.44** | **39.9%** | **23.9%** |
| ១.១ ចំណូលចរន្ត | **11,353.45** | **1,574.75** | **1,531.45** | **1,480.86** | **1,960.87** | **2,089.24** | **2,072.51** | **40.0%** | **23.9%** |
| ចំណូលសារពើពន្ធ | **10,179.39** | 1,436.83 | 1,375.11 | 1,220.88 | 1,793.93 | 1,754.54 | 1,712.70 | **40.3%** | **23.6%** |
| ចំណូលមិនមែនសារពើពន្ធ | **1,174.06** | 137.91 | 156.34 | 259.99 | 166.94 | 334.70 | 359.81 | **38.4%** | **26.8%** |
| ១.២ ចំណូលមូលធន | **60.73** | - | **16.59** | **18.4** | **0.13** | **25.96** | **24.93** | **35.5%** | **18.1%** |
| **២. ចំណាយសរុប** | **8,815.69** | **1,546.00** | **1,656.76** | **2,189.81** | **1,690.51** | **1,576.12** | **1,879.33** | **-14.2%** | **2.1%** |
| ២.១ ចំណាយចរន្ត | **6,422.35** | **1,143.58** | **1,101.71** | **1,442.14** | **1,215.48** | **1,269.65** | **1,403.32** | **-2.7%** | **5.7%** |
| ចំណាយបៀវត្ស | **3,634.22** | 650.99 | 693.53 | 732.43 | 619.72 | 654.88 | 725.15 | **-1.0%** | **-1.0%** |
| ចំណាយមិនមែនបៀវត្ស | **2,788.13** | 492.59 | 408.18 | 709.71 | 595.76 | 614.76 | 678.18 | **-4.4%** | **15.7%** |
| ២.២ ចំណាយមូលធន | **2,393.33** | **402.42** | **555.05** | **747.67** | **475.03** | **306.47** | **476.01** | **-36.3%** | **-6.8%** |
| ការកែតម្រូវចំណាយ | - | - | - | - | - | - | - | - | - |

| | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|
| **តុល្យភាពចរន្ត (សាច់ប្រាក់)** | **4,931.09** | **431.17** | **429.75** | **38.72** | **745.39** | **819.59** | **669.18** | - | - |
| **តុល្យភាពទូទៅ (សាច់ប្រាក់)** | **2,598.49** | **28.74** | **(108.72)** | **(690.55)** | **270.49** | **539.09** | **218.10** | - | - |

*ប្រភពទិន្នន័យ÷ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ*

*សម្គាល់÷ ក្នុងតារាង (,) ស្មើកាត់ខ្ទង់ និង (.) ស្មើក្បៀស*

## ១.៥. ស្ថានភាពវិនិយោគ / Investment

**តារាង ១.៥÷ ស្ថានភាពវិនិយោគក្នុងខែកក្កដា ឆ្នាំ២០១៩**

| សូចនាករ | ឯកតា | ២០១៥ ១២ខែ | ២០១៦ ១២ខែ | ២០១៧ ១២ខែ | ២០១៨ ១២ខែ | ២០១៩ | | | | Δ% | |
|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | | ឧសភា | មិថុនា | កក្កដា | ៧ខែ | ខែមុន | ៧ខែឆ្នាំមុន |
| ចំនួនគម្រោង | គម្រោង | 124 | 121 | 117 | 148 | 5 | 19 | 22 | 122 | **3*** | **53*** |
| ចំនួនទុនវិនិយោគ | លាន($) | 3,919 | 3,249 | 5,217 | 5,804 | 39 | 1,001 | 113 | 4,736 | **-89%** | **62.6%** |
| ចំនួនការងារបង្កើត | ពាន់នាក់ | 144 | 127 | 137 | 178 | 8 | 23 | 20 | 162 | **-12%** | **98.4%** |

*ប្រភព÷ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា*

*សម្គាល់÷ ១)*គិតជាចំនួនគម្រោង ២)ក្នុងតារាង (,) ស្មើកាត់ខ្ទង់ និង (.) ស្មើក្បៀស*

## ១.៦. ស្ថានភាពទេសចរណ៍ / Tourism

**តារាង ១.៦÷ ចំនួនភ្ញៀវអន្តរជាតិក្នុងខែកក្កដា ឆ្នាំ២០១៩ (ពាន់នាក់)**

| សូចនាករសំខាន់ៗ | ២០១៥ ១២ខែ | ២០១៦ ១២ខែ | ២០១៧ ១២ខែ | ២០១៨ ១២ខែ | ២០១៩ | | | | Δ% | |
|---|---|---|---|---|---|---|---|---|---|---|
| | | | | | ឧសភា | មិថុនា | កក្កដា | ៧ខែ | ខែមុន | ៧ខែឆ្នាំមុន |
| **សរុប** | **4,775** | **5,012** | **5,602** | **6,201** | **473** | **450** | **502** | **3,841** | **11.6%** | **11.1%** |
| **តាមអាកាស** | **2,476** | **2,704** | **3,313** | **4,097** | **343** | **335** | **381** | **2,735** | **13.8%** | **18.3%** |
| ច្រកអន្តរជាតិភ្នំពេញ | 1,061 | 1,164 | 1,410 | 1,924 | 165 | 158 | 176 | 1,258 | **11.5%** | **17%** |
| ច្រកសៀមរាប | 1,415 | 1,507 | 1,821 | 1,940 | 116 | 105 | 117 | 1,068 | **10.9%** | **-7.1%** |
| ច្រកកងកេង | - | 33 | 82 | 234 | 62 | 72 | 88 | 409 | **22.8%** | **362.6%** |
| **តាមផ្លូវគោកនិងទឹក** | **2,299** | **2,307** | **2,289** | **2,104** | **130** | **115** | **121** | **1,106** | **5.5%** | **-3.2%** |
| ផ្លូវគោក | 2,151 | 2,154 | 2,144 | 1,960 | 126 | 112 | 118 | 1,015 | **5.3%** | **-3.9%** |
| ផ្លូវទឹក | 148 | 153 | 145 | 144 | 4 | 3 | 4 | 90 | **13.2%** | **5.2%** |

*ប្រភព÷ ក្រសួងទេសចរណ៍*

*សម្គាល់÷ ក្នុងតារាង (,) ស្មើកាត់ខ្ទង់ និង (.) ស្មើក្បៀស*

## ១.៧. ស្ថានភាពសំណង់ / Construction

| តារាង ១.៧÷ ស្ថានភាពសំណង់ក្នុងខែកក្កដា ឆ្នាំ២០១៩ | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|
| សូចនាករ | ឯកតា | ២០១៥ ១២ខែ | ២០១៦ ១២ខែ | ២០១៧ ១២ខែ | ២០១៨ ១២ខែ | ២០១៩ | | | | Δ % | |
| | | | | | | ឧសភា | មិថុនា | កក្កដា | ៧ខែ | ខែមុន | ៧ខែឆ្នាំមុន |
| សរុបចំនួនគម្រោង | ចំនួន | 2,070 | 2,636 | 3,418 | 3,294 | 287 | 340 | 525 | 2,477 | **185*** | **500*** |
| សរុបជាផ្ទៃក្រឡា | ពាន់ម២ | 7,766 | 12,158 | 11,382 | 12,569 | 300 | 993 | 2,160 | 9,108 | **117.6%** | **24%** |
| សរុបជាទឹកប្រាក់ | លាន($) | 3,335 | 5,580 | 6,799 | 5,755 | 152 | 498 | 1,173 | 4,544 | **135.5%** | **51.6%** |

*ប្រភព÷ ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់*

*សម្គាល់÷ ១)* គិតជាចំនួនគម្រោង ២)ក្នុងតារាង (,) ស្មើកាត់ខ្ទង់ និង (.) ស្មើក្បៀស*

## ២. និន្នាការថ្លៃទំនិញសំខាន់ៗ / Commodity prices

| តារាង២÷ស្ថានភាពថ្លៃទំនិញសំខាន់ៗ (ថ្លៃមធ្យមប្រចាំខែ) | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|
| សូចនាករសំខាន់ៗ | | ឯកតា | ២០១៨ | | | ២០១៩ | | | △ផលធៀបជាភាគរយ | |
| | | | ឧសភា | មិថុនា | កក្កដា | ឧសភា | មិថុនា | កក្កដា | ខែមុន | ឆ្នាំមុន |
| ក្នុងស្រុក | សាំងស៊ូពែរ (EA 95) | រៀល/ លីត្រ | 4,525 | 4,563 | 4,225 | 4,275 | 4,025 | 4,050 | 0.62% | -4.14% |
| | សាំងធម្មតា (EA 92) | រៀល/ លីត្រ | 4,175 | 4,213 | 3,950 | 3,875 | 3,625 | 3,675 | 1.38% | -6.96% |
| | ម៉ាស៊ូត (DO 0.05%) | រៀល/ លីត្រ | 4,000 | 4,013 | 3,750 | 3,675 | 3,525 | 3,525 | 0.00% | -6.00% |
| | ហ្គាស | រៀល/១៥គ.ក្រ | 64,000 | 64,000 | 64,000 | 64,320 | 65,090 | 65,176 | 0.13% | 1.84% |
| | អង្ករកម្ពុជា (លេខ១) | រៀល/ គ.ក្រ | 3,540 | 3,565 | 3,640 | 3,680 | 3,680 | 3,680 | 0.00% | 1.10% |
| | អង្ករកម្ពុជា (លេខ២) | រៀល/ គ.ក្រ | 2,670 | 2,550 | 2,540 | 2,760 | 2,760 | 2,760 | 0.00% | 8.66% |
| | ម្រេច | រៀល/ គ.ក្រ | 27,800 | 27,900 | 28,000 | 28,950 | 28,600 | 28,600 | 0.00% | 2.14% |
| | កៅស៊ូគ្រួសារ (ជ័រស្ងួត) | រៀល/ គ.ក្រ | 4,520 | 4,425 | 4,045 | 4,200 | 5,267 | 5,150 | -2.22% | 27.32% |
| អន្តរជាតិ | Average Oil Price | ដុល្លារ/ បារ៉ែល | $73.43 | $71.98 | $72.67 | $66.83 | $59.76 | $61.48 | 2.88% | -15.40% |
| | Brent | ដុល្លារ/ បារ៉ែល | $76.65 | $75.19 | $74.44 | $70.53 | $63.30 | $64.00 | 1.11% | -14.02% |
| | Dubai | ដុល្លារ/ បារ៉ែល | $73.66 | $73.22 | $72.72 | $69.13 | $61.30 | $62.91 | 2.63% | -13.49% |
| | WTI | ដុល្លារ/ បារ៉ែល | $69.98 | $67.52 | $70.84 | $60.84 | $54.68 | $57.52 | 5.19% | -18.80% |
| | សាំងធម្មតា (US) | ដុល្លារ/ លីត្រ | $0.79 | $0.78 | $0.77 | $0.78 | $0.74 | $0.75 | 0.93% | -3.39% |
| | អង្ករថៃ (5%) | ដុល្លារ/ តោន | $451 | $427 | $398 | $409 | $420 | $416 | -0.95% | 4.52% |
| | អង្ករវៀតណាម (5%) | ដុល្លារ/ តោន | $419 | $443 | $441 | $351 | $359 | $360 | 0.37% | -18.27% |
| | អង្ករថៃ (25%) | ដុល្លារ/ តោន | $436 | $415 | $390 | $401 | $411 | $409 | -0.49% | 4.87% |

| | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|
| | អង្ករថៃ A.1 (100%) | ដុល្លារ/តោន | $432 | $409 | $383 | $387 | $394 | $392 | -0.63% | 2.34% |
| | កៅស៊ូ (TSR20) | ដុល្លារ/តោន | $1,446 | $1,410 | $1,341 | $1,587 | $1,650 | $1,508 | -8.61% | 12.46% |
| | កៅស៊ូ (RSS3) | ដុល្លារ/តោន | $1,751 | $1,630 | $1,501 | $1,795 | $2,015 | $1,824 | -9.48% | 21.49% |

*ប្រភព÷ ក្រសួងពាណិជ្ជកម្ម, ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ, World Bank, Association of Natural Rubber Producing Countries, Global Rubber Market (Asia Market), សហព័ន្ធស្រូវអង្ករកម្ពុជា, Mekong Oryza, General Directorate of Rubber, etc.*

**<u>កំណត់សម្គាល់</u>**

កៅស៊ូ÷

- កៅស៊ូ TSR20: ឬហៅថាកៅស៊ូស្តង់ដារលេខ២០ រួមមានកៅស៊ូ SIR20, SMR20 និង STR20 គឺសំដៅលើកៅស៊ូធម្មជាតិដែលមានសារធាតុផ្សេងៗទៀត២០%។ កៅស៊ូធម្មជាតិមានច្រើនប្រភេទ ក្នុងនោះកៅស៊ូដែលមានតម្រូវការប្រើប្រាស់ច្រើនជាងគេគឺកៅស៊ូស្តង់ដារ (កៅស៊ូដុំ) និងកៅស៊ូបន្ទះ។ កៅស៊ូ TSR20 ជាប្រភេទកៅស៊ូដែលបានកែច្នៃក្នុងកម្រិតខ្ពស់ ប្រើប្រាស់សម្រាប់ ផលិតកម្មកង់ឡាន បំពង់ទីបជ័រ កម្រាលជ័រ ស្បែកជើងនិងអាវភ្លៀងជាដើម។ កៅស៊ូប្រភេទនេះមានកម្រិតស្អិតទាប ហើយងាយលាយបញ្ចូល ជាមួយសារធាតុដទៃ ដែលធ្វើឱ្យផលិតផលផលិតចេញពីកៅស៊ូនេះមានភាពរឹងមាំ ធន់និងមិនងាយសឹករិចរិល។ ប្រទេសសំខាន់ៗដែលផលិតកៅស៊ូប្រភេទនេះគឺម៉ាឡេស៊ី ថៃ ឥណ្ឌូណេស៊ី វៀតណាម និងចិន។
- កៅស៊ូ RSS (Ribbed Smoked Sheets) បែងចែកជា៦ប្រភេទគឺ ប្រភេទលេខ 1, 2, 3, 4, 5 និងប្រភេទពិសេស មានពណ៌លឿងនិងវេចខ្ចប់ជាបន្ទះ។ កៅស៊ូប្រភេទ RSS3 ច្រើនផលិតនៅប្រទេសថៃ ឥណ្ឌា និងឥណ្ឌូណេស៊ី ប្រើប្រាស់ជាវត្ថុធាតុ សម្រាប់ផលិតសំបកកង់រថយន្ត បំពង់ទីបជ័រ និងស្បែកជើង។ កៅស៊ូប្រភេទនេះប្រើប្រាស់ក្នុងឧស្សាហកម្មផលិតសំបកកង់ រថយន្ត និងដែលជាធាតុផ្សំលើស 50% នៃផលិតផល។

ប្រេងឆៅ÷

ប្រេងឆៅ Brent, WTI និង Dubai ជាប្រភេទប្រេងឆៅធុនស្រាល (Light Crude Oil) ដែលមានការទិញលក់ច្រើនជាងគេ និងជាថ្លៃមូលដ្ឋានក្នុងការទិញលក់កិច្ចសន្យាអនាគត (Future Contract)។ ប្រេងឆៅលើទីផ្សារអន្តរជាតិមានលក្ខណៈខុសគ្នា ទៅតាមប្រភេទដូចជា÷ ប្រភេទប្រេង Brent ច្រើនផលិតនៅតំបន់សមុទ្រអាត្លង់ទិចខាងជើង, ប្រភេទប្រេងរបស់អាមេរិក WTI (West Texas Intermediate) និងប្រភេទប្រេងរបស់អារ៉ាប់ប៊ីសាអ៊ូឌីត Dubai។ ប្រភេទប្រេងឆៅទាំងបីមានលក្ខណៈ ខុសគ្នាទៅតាមកម្រិតភាពស្រាល ហើយប្រភេទប្រេងឆៅដែលមានភាពស្រាលជាងគេអាចចម្រាញ់ជាប្រេងឥន្ធនៈបានច្រើន។ API Gravity ត្រូវបានគេប្រើប្រាស់វាស់វែងភាពស្រាលនៃប្រភេទប្រេងឆៅនីមួយៗ។ ប្រភេទប្រេងដែលមានកម្រិត API Gravity កាន់តែខ្ពស់គឺជាប្រភេទប្រេងដែលកាន់តែស្រាល និងអាចចម្រាញ់ជាប្រេងឥន្ធនៈបានច្រើន។

- WTI 40$^{o}$ API
- Brent 38$^{o}$ API
- Dubai 32$^{o}$ API

*រៀបចំដោយ*

*នាយកដ្ឋានស្ថិតិនិងវិភាគសេដ្ឋកិច្ច*

*អគ្គនាយកដ្ឋានគោលនយោបាយ*

*ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ*

*ព័ត៌មានផ្សេងៗ សូមទាក់ទងក្រុមការងារ*

*ទូរស័ព្ទលេខ÷ ០២៣ ៤២៧ ៩១៣, ០៩៨ ២២ ៨៤ ៩៤*

*ម៉ោងធ្វើការ÷ ៨:០០ ដល់ ១២:០០ព្រឹក និង ២:០០ ដល់ ៥:០០រសៀល*